# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

២៣-១០-២០០៦ -ព្រះរាជក្រម នស/រកម/១០០៦/០២៥ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីលក្ខន្តិកៈ តំណាងរាស្ត្រ ៧០៨៥

### ២~ព្រះរាជក្រឹត្យ

១៣-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤១៥ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ចូតូបនីយកម្ម ដល់លោក **ចាង ដុងជី** ( CHANG DONG GI ) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ក្រុងវីសាន សាធារណរដ្ឋកូរ៉េ ៧០៩៥

២០-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤២២ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០៨ រូបជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា ៧០៩៦

២១-១០-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១០០៦/៤២៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ចូតូបនីយកម្ម ដល់លោក **ហុង ឈាន់ម៉ីង** ( HUNG CHUANG MING ) ជនជាតិចិន សញ្ជាតិចិន កើតនៅ ស្រុកតុងគួង ខេត្តក្វាងតុង ប្រទេសចិន ៧០៩៧

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

២៤-១០-២០០៦ -អនុក្រឹត្យលេខ ១១១ អនក្រ.បក ស្តីពីការប្តូរឈ្មោះ សាកលវិទ្យាល័យអាស៊ាន ទៅជា សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ៧០៩៨

២៥-១០-២០០៦ -អនុក្រឹត្យលេខ ១១២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧១០១

២៥-១០-២០០៦ -អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ៧១០៣

២៥-១០-២០០៦ -អនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧១០៦

២៥-១០-២០០៦ -អនុក្រឹត្យលេខ ៦៩១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៧១០៨

២៥-១០-២០០៦ -អនុក្រឹត្យលេខ ៦៩២ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៧១០៩

២៥-១០-២០០៦ -អនុក្រឹត្យលេខ ៦៩៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧១១១

២៥-១០-២០០៦ -អនុក្រឹត្យលេខ ៦៩៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ៧១១២

២៦-១០-២០០៦ -អនុក្រឹត្យលេខ ៦៩៥ អនក្រ.តត ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន ៧១១៣

## ២. សេចក្តីសម្រេច

២៥-១០-២០០៦ -សេចក្តីសម្រេចលេខ ៤៥ សសរ ស្តីពីការកែសម្រួលសមាសភាព នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ៧១១៥

## ៣. សារាចរ

២៣-១០-២០០៦ -សារាចរលេខ ០៣ សរ ស្តីពីការអនុវត្តនីតិវិធានការអប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ៧១១៧

## III. ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៤-១០-២០០៦ -ប្រកាសលេខ ១០១៥ សហវ.ប្រក.តរ ស្តីពីការបង្កើតក្រុមសម្របសម្រួលអន្តរស្ថាប័ននៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ ៧១២០

### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៥-១០-២០០៦ -ប្រកាសលេខ ១១៤៧ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន **ឡូទុសតី តិចស្តាយ ហ្គាមេន (ខេមបូឌា)** បង្កើតសាខារោងចក្រ "សំរាប់រៀបចំដាក់ម៉ាស៊ីនដេរ និងធ្វើជាឃ្លាំងស្តុកវត្ថុធាតុដើម និង ទំនិញត្រៀមនាំចេញ " ដែលមានឈ្មោះថា " ឡូទុសតី តិចស្តាយ ហ្គាមេន (ខេមបូឌា) សាខាទី ២ " ៧១២៤

២៧-១០-២០០៦ -ប្រកាសលេខ ១១៦២ ឧរថ.កឧ.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន **មករា ភ្នំមាស (ខេមបូឌា)** បង្កើតរោងចក្រ "កែច្នៃ ជួសជុលបំណែកយានយន្ត (កាងរថយន្តចាស់ៗ) " ដែលមានឈ្មោះថា " មករា ភ្នំមាស (ខេមបូឌា) " ៧១២៦

### ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៨៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មីនើរ៉ល ឌីវេឡុបមេន គ្រុប** ៧១២៨

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៩០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខែលឡា** ៧១៣០

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៩២ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **៧ អិនជី គ្រុប** ៧១៣២

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី_ហ្វម៉ូស** ៧១៣៤

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តុង មិន គ្រេឌីង (ខេមបូឌា)** ៧១៣៦

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស ប៊ី ជី** ៧១៣៨

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី.ទី អ៊ិនវេសមេន** ៧១៤០

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២០៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធីគ្រេឌ្គាល អេនជីនារីង លីមីធីត** ៧១៤២

១៦-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១០០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូ ឡាយហ្វ៍ អេនធើប្រាយ (ខេមបូឌា)** ៧១៤៤

១៧-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូតែលកូ** ៧១៤៦

១៧-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **៨៨៨ ខបតើរេសិន** ៧១៤៨

១៧-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១០៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊្លូ ស៊ី អ៊ីមផត អិចផត** ៧១៥០

១៧-៨-២០០៦ -លិខិតបញ្ជាក់លេខ ២១០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គូដ ឡាក់ អេគ្រ្វីខលឈ័រ** ៧១៥២

# ព្រះរាជក្រម

នស/រកម/១០០៦/០២៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

2/102

# ច្បាប់

# ស្តីពី

# លក្ខន្តិកៈតំណាងរាស្ត្រ

10ᴧ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់នូវអភ័យឯកសិទ្ធិសភា ឋានៈនិងបុព្វសិទ្ធិ វិសមិតភាព និងល័ក្ខខ័ណ្ឌចាំបាច់នានា ដើម្បីធានាជូនតំណាងរាស្ត្របំពេញភារកិច្ចស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

តំណាងរាស្ត្រដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ក្រោយពីបានប្រកាសសុពលភាព និងស្បថចូលកាន់តំណែងរួចហើយ គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ញាទាំងឡាយត្រូវទុកជាមោឃៈ ។

**មាត្រា ៣.-**

តំណាងរាស្ត្រមានអាណត្តិ ៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលតំណាងរាស្ត្រថ្មីចូលកាន់តំណែង ។

## ជំពូកទី ២
## អភ័យឯកសិទ្ធិសភា

**មាត្រា ៤.-**

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។ អភ័យឯកសិទ្ធិសភា ត្រូវបានចែកចេញជាពីរផ្នែក :

-ការធានាក្នុងការបញ្ចេញយោបល់ ឬ ការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយរបស់តំណាងរាស្ត្រ នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាតំណាងរាស្ត្រ គឺជាអភ័យឯកសិទ្ធិដាច់ខាតរបស់តំណាងរាស្ត្រ ។

-ការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនតំណាងរាស្ត្រណាមួយ គឺជាអភ័យឯកសិទ្ធិដោយប្រៀបរបស់តំណាងរាស្ត្រ ។

**មាត្រា ៥.-**

តំណាងរាស្ត្រមិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិសភានេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

**មាត្រា ៦.-**

តំណាងរាស្ត្រត្រូវគោរពបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧.-**

តំណាងរាស្ត្រណាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នឹងអាចអនុញ្ញាតបើកឱ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន ។

**មាត្រា ៨.-**

សេចក្តីស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្របណាមួយត្រូវធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផងផ្ញើជូនប្រធានរដ្ឋសភា ។

**មាត្រា ៩.-**

ការលើកអភ័យឯកសិទ្ធិសភាក្នុងរយៈពេលសម័យប្រជុំរដ្ឋសភាត្រូវអនុវត្តនីតិវិធីដូចខាងក្រោមនេះ :

-រដ្ឋសភាអាចប្រជុំជាសម្ងាត់ តាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ឬ ពីនាយករដ្ឋមន្ត្រី ។

-កូរ៉ុមប្រជុំលើសពីពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

-ការអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១០.-**

ការលើកអភ័យឯកសិទ្ធិសភាក្នុងចន្លោះសម័យប្រជុំរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវប្រជុំនិងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**មាត្រា ១១.-**

សេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១២.-**

ក្នុងករណីតំណាងរាស្ត្រណាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្ដែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នៅចន្លោះសម័យប្រជុំរដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

**មាត្រា ១៣.-**

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១៤.-**

តំណាងរាស្ត្រដែលអភ័យឯកសិទ្ធិត្រូវបានលើក ហើយស្ថិតក្នុងការចោទប្រកាន់របស់តុលាការ មានសិទ្ធិ និងបុព្វសិទ្ធិដូចតំណាងរាស្ត្រទូទៅ ។

តំណាងរាស្ត្រដែលស្ថិតក្នុងការចាប់ខ្លួន ឬ ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្ដោះអាសន្ន ត្រូវបាត់បង់សិទ្ធិចូលរួមប្រជុំរដ្ឋសភា និងគណៈកម្មការផ្សេងៗ ប៉ុន្តែមានសិទ្ធិទទួលប្រាក់បំណាច់របៀវត្សលែងតែប្រាក់បំណាច់ប្រជុំ ប្រាក់បេសកកម្ម ប្រាក់ប្រេងឥន្ធនៈ ។

10

តំណាងរាស្ត្រដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថាជាទណ្ឌិត ជាប់ពន្ធនាគារត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភា ។

**មាត្រា ១៥.-**

តំណាងរាស្ត្រូបណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោស តំណាងរាស្ត្រូបនោះនឹងបានទទួលសុពលភាព អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិឡើងវិញ ។

**មាត្រា ១៦.-**

តំណាងរាស្ត្រណាដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថា ជាជនគ្មានទោស តំណាងរាស្ត្រនោះត្រូវបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពេញលេញឡើងវិញ ។

## ជំពូកទី ៣
## វិសមិតភាព

**មាត្រា ១៧.-**

អាណត្តិនៃតំណាងរាស្ត្រមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

**មាត្រា ១៨.-**

តំណាងរាស្ត្រដែលបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល មានឋានៈជាតំណាងរាស្ត្រធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភាឡើយ ។

**មាត្រា ១៩.-**

តំណាងរាស្ត្រក្នុងតំណែងមានវិសមិតភាពជាមួយនឹងមុខងារជាមេធាវីដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

## ជំពូកទី ៤
## ប្រាក់បំណាច់ ឋានៈ និងបុព្វសិទ្ធិ

**មាត្រា ២០.-**

រដ្ឋសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

តំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីជុតលេខនៃព្រះរាជាណាចក្រកម្ពុជា ។

តំណាងរាស្ត្រគ្រប់រូបត្រូវបានទទួលនូវការធានារ៉ាប់រងសង្គមនៅក្នុងអាណត្តិរបស់ខ្លួន ។ ក្នុងករណីដែលតំណាងរាស្ត្រទទួលអនិច្ចកម្មនៅក្នុងអាណត្តិ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវទទួលបន្ទុករៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងដល់គ្រួសារសពរយៈពេលមួយឆ្នាំទៀត គិតចាប់ពីថ្ងៃទទួលអនិច្ចកម្ម ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវរៀបចំរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម របបធានាជម្ងឺ របបប្រាក់សោធននិវត្តន៍ របបបេសកកម្ម និងល័ក្ខខ័ណ្ឌធ្វើការងាររបស់តំណាងរាស្ត្រ ។

**មាត្រា ២១.-**

តំណាងរាស្ត្រទទួលប្រាក់សោធននិវត្តន៍ ។

ប្រាក់សោធននិវត្តន៍របស់តំណាងរាស្ត្រ បើកនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

ប្រាក់សោធននិវត្តន៍ បើកបានតែមួយកន្លែងគត់ ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវសម្រេចឱ្យតំណាងរាស្ត្រចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២២.-**

ល័ក្ខខ័ណ្ឌទាំងឡាយដែលអតីតតំណាងរាស្ត្រទទួលបានប្រាក់សោធននិវត្តន៍ :

ក-ជាតំណាងរាស្ត្រគិតចាប់តាំងពីឆ្នាំ ១៩៩៣ មក ។

4

/101.

ខ-មានអាយុចាប់ពី ៦០ (ហុកសិប) ឆ្នាំ ឡើង ។

គ-មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។

**មាត្រា ២៣.-**

រូបមន្តសំរាប់គណនារៀបចំរបបសោធននិវត្តន៍របស់អតីតតំណាងរាស្ត្រ ត្រូវផ្អែកលើប្រាក់បំណាច់តំណាងរាស្ត្រ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង រយៈពេលមួយឆ្នាំរបស់តំណាងរាស្ត្រម្នាក់ៗនៃឆ្នាំចុងក្រោយ កំណត់ស្មើនឹង ១០០% (មួយរយភាគរយ) ។

ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ :

| | |
|---|---|
| -ពី ១ឆ្នាំ ដល់ ៣ឆ្នាំ ទទួលបានសន្ទស្សន៍ | ០,៥ % |
| -លើសពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ ទទួលបានសន្ទស្សន៍ | ១ % |
| -ពី ៦ឆ្នាំ ដល់ក្រោម ១១ឆ្នាំ ទទួលបានសន្ទស្សន៍ | ២ % |
| -ពី ១១ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ទទួលបានសន្ទស្សន៍ | ៣ % |
| -ពី ១៦ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ | ៤ % |
| -ចំពោះតំណាងរាស្ត្រក្នុងតំណែងបីអាណត្តិបន្តបន្ទាប់គ្នា ទទួលបានសន្ទស្សន៍ | ៤ % |

អតីតតំណាងរាស្ត្រទទួលប្រាក់សោធននិវត្តន៍ប្រចាំខែរហូតដល់ទទួលមរណភាព វៀរលែងតែត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រ ។

**មាត្រា ២៤.-**

អតីតតំណាងរាស្ត្រដែលមិនជាប់ឆ្នោតឡើងវិញ ក្រោយពីមានអាយុគ្រប់ ៦០ (ហុកសិប) ឆ្នាំ អាចទទួលបានប្រាក់សោធននិវត្តន៍ ដោយបើកផ្តាច់ត្រឹមរយៈពេលតែមួយឆ្នាំគត់បាន ។

**មាត្រា ២៥.-**

តំណាងរាស្ត្រមានអ្នកជំនួយការមួយចំនួន ដែលជួយធ្វើការងារតាមល័ក្ខខ័ណ្ឌបុគ្គលិកជាប់កិច្ចសន្យា ដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ឯប្រាក់កំរៃជា

4

110

បន្ទុករបស់ថវិការដ្ឋសភា ។

ដើម្បីមានភាពងាយស្រួលក្នុងការបំពេញការងារ អគ្គលេខាធិការដ្ឋានរដ្ឋសភាជួយដល់តំណាងរាស្ត្រ តាមបែបបទកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**មាត្រា ២៦.-**

តំណាងរាស្ត្រក្នុងតំណែងត្រូវទទួលបាននូវ :

-ប័ណ្ណសំគាល់អភ័យឯកសិទ្ធិ

-រូបសញ្ញារដ្ឋសភាសំរាប់ពាក់លើអាវ

-រូបសញ្ញាបារមីរបស់រដ្ឋសភា

-ផ្លាករថយន្តរដ្ឋសភា

-លិខិតឆ្លងដែនការទូតផ្ទាល់ខ្លួន សហព័ទ្ធ និងកូនអាយុក្រោម ១៨ឆ្នាំ

-ឯកសណ្ឋានរដ្ឋសភា

-គ្រឿងឥស្សរិយយសពីរដងក្នុងមួយអាណត្តិ

-ការធានារ៉ាប់រងជម្ងឺ នៅក្នុងមន្ទីរពេទ្យរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយថវិការបស់រដ្ឋសភា ។

**មាត្រា ២៧.-**

មន្ត្រីរាជការស៊ីវិល ឬ កងកំលាំងប្រដាប់អាវុធ ដែលជាប់ឆ្នោតជាតំណាងរាស្ត្រ ត្រូវបានឡើងឋានន្តរសក្តិ ឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពសម្រាប់ទទួលសោធន-និវត្តន៍ ។

**មាត្រា ២៨.-**

តំណាងរាស្ត្រក្នុងតំណែងត្រូវបានទទួលងារជា ឯកឧត្តម ឬ លោកជំទាវ ។ អតីតតំណាងរាស្ត្រ ក្រោយពេលដែលបានបញ្ចប់អាណត្តិហើយ ត្រូវបានរក្សាងារជា ឯកឧត្តម អតីតតំណាងរាស្ត្រ ឬ លោកជំទាវអតីតតំណាងរាស្ត្រ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣រល.០៦១០.៤៥១

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ :៤០៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ១០ ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចាង ដុងជី** ( CHANG DONG GI ) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៥២ នៅសាធារណរដ្ឋកូរ៉េ ។

**មាត្រា២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ តុលា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

៣រល.០៦១០.៤៣៩

លេខ:៣៩៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃួន ឌីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤២២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

**<u>ត្រាស់បង្គាប់</u>**

<u>មាត្រា១</u> : ត្រូវបានតែងតាំង:

១- ឯកឧត្តម **មិត្ត ការ៉េន** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- ឯកឧត្តម **ឡាច លៀង** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- ឯកឧត្តម **ស៊ឹម ចាន់** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ ។

៤- ឯកឧត្តម **ទ្រាក់ សុម៉ាលី** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ ។

៥- ឯកឧត្តម **ចាម សុទ្ធិ** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៦- ឯកឧត្តម **ឈុប ប៊ុនធឿន** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៧- ឯកឧត្តមបណ្ឌិត **សំ សារ៉ែន** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៨- ឯកឧត្តម **ឈួត នន់** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

<u>មាត្រា២</u> : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

<u>មាត្រា៣</u> : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

ចរល. ០៦១០.៤៤៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ . ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៦

លេខ: ៤០៥ [illegible]
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០០៦
[illegible]
[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/១០០៦/៤២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ឯកឧត្តម នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១: ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ហុង ឈាន់ម៉ីង ( HUNG CHUANG MING ) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០៣ ខែតុលា ឆ្នាំ១៩៦២ នៅស្រុកគុងកួង ខេត្តក្វាងតុង ប្រទេសចិន ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្ត អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៦១០.៤៤៩

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦

លេខ : ៤០៣ ច.ល
បើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ១០ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ានិត

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១១១....អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះ សាកលវិទ្យាល័យអាស៊ាន
## ទៅជា សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យអាស៊ាន
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៣៥៧៩ អយក.ឧស ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៦

# ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់ការប្តូរឈ្មោះ **សាកលវិទ្យាល័យអាស៊ាន** ទៅជា **សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ** " **Phnom Penh International University** " ហៅកាត់ជាភាសាខ្មែរ " **ស.ភ.ព.អ** " និងហៅកាត់ជាភាសាអង់គ្លេស " **PPIU** " ។ សាកលវិទ្យាល័យនេះ មានទីតាំងគោលស្ថិតនៅ អាគារលេខ ១ ផ្លូវលេខ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេស ឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់ សាកលវិទ្យាល័យ ។
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- រៀបចំកម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់ ។
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព ។
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រតាមឯកទេសរបស់សាកលវិទ្យាល័យ ។
- កសាងផែនការអភិវឌ្ឍសម្រាប់ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- គ្រប់គ្រង និយោជិក កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានាក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរឡើង នូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

**មាត្រា ៤ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសិក្សារយៈពេលក្រោម ២ឆ្នាំ ថ្នាក់បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ ថ្នាក់បរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សាស្រាវជ្រាវ រយៈពេល ២ឆ្នាំ និងថ្នាក់បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេល ៣ឆ្នាំ ជាមធ្យម ដែលរចនាសម្ព័ន្ធសិក្សាត្រូវបានរៀបចំឱ្យមាន មហាវិទ្យាល័យ ចំនួន ០៤ និងមជ្ឈមណ្ឌលថ្នាក់ជំនាញវិជ្ជាជីវៈ ០១ គឺ :

- មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និងទេសចរណ៍
- មហាវិទ្យាល័យ នីតិសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា
- មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់វិជ្ជាជីវៈរយៈពេលខ្លី

ទៅអនាគត សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ អាចប្តូរឈ្មោះ ប្តូរទីតាំង ឬការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានឧត្តមសិក្សាបរទេស ការបង្កើតមហាវិទ្យាល័យ ឬសាខា ឬឯកទេស ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ ស.ភ.ព.អ និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨ :** សាកលវិទ្យាធិការមានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រង សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយ របស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល ។
- ធ្វើរបាយការណ៍គ្រប់គ្រងប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចដល់អង្គភាពនានាក្រោមឱវាទ ។
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ និងគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិក ។
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

**មាត្រា ៩ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ហើយមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ១០ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី២៥ ខែ ៧ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :..១១២...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤១០ លានរៀល ( បួនរយដប់លានរៀលគត់ ) ពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣០ ( អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច ) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូន :

| | | | |
|---|---|---|---|
| -រាជបណ្ឌិតសភាកម្ពុជា | ចំនួន | ១៥០ | លានរៀល |
| -ក្រុមសង្កេតការណ៍សេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ | ចំនួន | ១៥០ | លានរៀល |
| - រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | ចំនួន | ៦០ | លានរៀល |
| -គណៈកម្មការសិទ្ធិមនុស្សកម្ពុជា | ចំនួន | ៥០ | លានរៀល |

សំរាប់ធានាដំណើរការការងាររដ្ឋបាលបន្តរហូតដល់ដំណាច់ឆ្នាំ ២០០៦ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**អ៊ុក រ៉ាប៊ុន**

**រដ្ឋមន្ត្រីស្តីទី**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :.១១៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច

៤.១ នៃអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា ១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ** (SIHANOUKVILLE SEZ) ដែលមានទីតាំងស្ថិតនៅសង្កាត់អូរគ្រះ ខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ។

**មាត្រា ២.-**

**តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ** មានទំហំ មួយរយចិតសិបប្រាំបីហិកតា និងប្រាំមួយពាន់ពីររយម៉ែត្រក្រឡា ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រ ក្នុងឧបសម្ព័ន្ធដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់ របស់ក្រុមហ៊ុន ។

**មាត្រា ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលក្រុងព្រះសីហនុ និងក្រុមហ៊ុនខេមបូឌា អ៊ិនធើរណេស្យូណល អ៊ិនវេស្តមែន ឌីវើឡុបមែន គ្រុប ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ១០ ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

សុខ ចិន្តា

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤០០ លានរៀល (បួនរយលានរៀលគត់) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូន :

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចំនួន ៣៥០ លានរៀល

-គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ចំនួន ៥០ លានរៀល

សំរាប់ធានាដំណើរការការងាររដ្ឋបាលបន្តរហូតដល់ដំណាច់ឆ្នាំ ២០០៦ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- **ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី**
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត់ ចាន់ថុន

**រដ្ឋមន្ត្រីស្តីទី**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៩១ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំ រេ ច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្ដមសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **ភឿង ម៉េង** អត្តលេខ ០៦៣១
២- លោកវរសេនីយ៍ទោ **ឆាង និនសេ្ន** អត្តលេខ ០៦៤៦
៣- លោកវរសេនីយ៍ទោ **ស៊ រ មុន្នី** អត្តលេខ ០៦៦១
៤- លោកវរសេនីយ៍ទោ **សុខ ជួរ** អត្តលេខ ០៧៧៨
៥- លោកវរសេនីយ៍ទោ **ស៊ំ សុខា** អត្តលេខ ០១៣២៩ ។

**មាត្រា ២ :** **រដ្ឋមន្ត្រីទ**ទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៩៧.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១. | លោកវរសេនីយ៍ទោ | **សូ** | **ប៊ុនឡឿន** | អត្តលេខ ០៤២៥ |
| ២. | លោកវរសេនីយ៍ទោ | **យិន** | **ប៊ុនណាត** | អត្តលេខ ០៤២៦ |
| ៣. | លោកវរសេនីយ៍ទោ | **ស៊ាង** | **កុសល** | អត្តលេខ ០៤២៧ |
| ៤. | លោកវរសេនីយ៍ទោ | **ចាន់** | **ស៊ីផុន** | អត្តលេខ ០៤៣០ |
| ៥. | លោកវរសេនីយ៍ទោ | **តាក** | **វណ្ណថា** | អត្តលេខ ០៤៤៧ |
| ៦. | លោកវរសេនីយ៍ទោ | **ស៊ាង** | **លី** | អត្តលេខ ០៤៤៨ |
| ៧. | លោកវរសេនីយ៍ទោ | **ម៉ាង** | **អាន់** | អត្តលេខ ០៤៤៩ |
| ៨. | លោកវរសេនីយ៍ទោ | **ប្រាក់** | **ទុរ្លី** | អត្តលេខ ០៤៦៤ |

៩. លោកវរសេនីយ៍ទោ ឆុយ សុខណ្ណារ៉ា អត្តលេខ ០៤៦៦

១០. លោកវរសេនីយ៍ទោ ពូន សានិត អត្តលេខ ០៤៨៦

១១. លោកវរសេនីយ៍ទោ ខ្ញឹម តីលី អត្តលេខ ០៤៩៦

១២. លោកវរសេនីយ៍ទោ ហង្ស ស៊ីធីម អត្តលេខ ០៤៩៧

១៣. លោកវរសេនីយ៍ទោ ជូ សំអាន អត្តលេខ ០៤៩៨

១៤. លោកវរសេនីយ៍ទោ មាស សុផាន់ណា អត្តលេខ ០៥៣១

១៥. លោកវរសេនីយ៍ទោ ស៊ិន សារិទ្ធ អត្តលេខ ០៥៣៦

១៦. លោកវរសេនីយ៍ទោ ហេង ប៊ុនមី អត្តលេខ ០៦៣៣

១៧. លោកវរសេនីយ៍ទោ គឹម សាម៉ន អត្តលេខ ០៦៨៣ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ១០ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ - កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:.....៤៩៣.....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន០២រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការជួយឧបត្ថម្ភដល់ការកសាង និងអភិវឌ្ឍន៍លើវិស័យនានាជាច្រើនកន្លែង នៅទូទាំងប្រទេសកម្ពុជា ហើយថ្មីៗនេះទៀត គ្រោងនឹងបើកកម្មវិធី *"មូលនិធិ បណ្ឌិត ហារុហ៊ីសា ហាន់ដា"* ដែលនឹងធ្វើការចែកអំណោយ ឧបត្ថម្ភដល់ប្រជាពលរដ្ឋកម្ពុជា ដែលរងគ្រោះដោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម ចំនួន ១០.០០០គ្រួសារ ក្នុងចំនួនទឹកប្រាក់សរុប ១.០០០.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម បណ្ឌិត **កៅ គឹមហួន** ប្រធានសាកលវិទ្យាល័យកម្ពុជា

២-លោក បណ្ឌិត **ហារុហ៊ីសា ហាន់ដា** ប្រធានអង្គការ World Mate និងជាប្រធានមូលនិធិអន្តរជាតិដើម្បីសិល្បៈវប្បធម៌ នៃប្រទេសជប៉ុន

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៦*

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៩៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានតម្លើងឋានន្តរស័ក្តិលោក **ឆាយ ទ៉ិត** ពីឋានន្តរស័ក្តិអនុមន្ត្រីថ្នាក់លេខ **៩** ទៅឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ **១០** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យរបស់ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១ៈ** ត្រូវបានតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-ឧត្តមសេនីយ៍ទោ **អ៊ូ សារ៉ុម** អត្តលេខ ០០០៣៣២ នាយកទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយកទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការដ្ឋាន

២-ឧត្តមសេនីយ៍ត្រី **សេង ឫទ្ធី** អត្តលេខ ០០១១៨១ នាយករងខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយកទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន

៣-ឧត្ដមសេនីយ៍ត្រី **ខ្មៅ សារ៉ាត់** អត្តលេខ ០០០២៨២ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

៤-ឧត្ដមសេនីយ៍ត្រី **ផាន់ សិដ្ឋ** អត្តលេខ ០០៤៣២១ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៥-វរសេនីយ៍ឯក **នេត សារឿន** អត្តលេខ ០០០៥០៤ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

៦-វរសេនីយ៍ឯក **ចាន់ ខេមរៈ** អត្តលេខ ០០០៤៨៧ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

៧-វរសេនីយ៍ឯក **គង់ សិទ្ធ** អត្តលេខ ០០០៨៦១ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

**មាត្រា២:** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងបណ្ដាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ១៧ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- **ដូចមាត្រា ២**
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាព នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៨៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ៦២ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាជិក-សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានតែងតាំង ឯកឧត្តម **ធេព នន្ទរី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ជំនួសឯកឧត្តម **គង់ ហ៊ុនធារិទ្ធិ** ដែលត្រូវបានផ្លាស់ចេញពីតំណែង ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ដូចប្រការ ៣*
- ***រាជកិច្ច***
- ***ឯកសារ**-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :...០៣...សរ.ណ**

# សារាចរ

## ស្តីពី

## ការអនុវត្តន៍វិធានការអប់រំ ព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន

ដោយពិនិត្យឃើញថា សភាពការណ៍ប្រើប្រាស់បំពានគ្រឿងញៀន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការកើនឡើងគួរអោយកត់សំគាល់ក្នុងចំណោម កម្មករ ពលករ ពិសេសក្នុងស្រទាប់យុវវ័យ ដែលជានិន្នាការឈានទៅរកការបាត់បង់ធនធានមនុស្ស ប៉ះពាល់ដល់សេដ្ឋកិច្ច សង្គមកិច្ច រាំងស្ទះដំណើរការអភិវឌ្ឍន៍ ប្រទេសជាតិ បង្កើតក្តីកង្វល់ចំពោះរាជរដ្ឋាភិបាល សហគមន៍ គ្រួសារ ព្រមទាំងបន្សល់ទុកនូវអ្នករងគ្រោះ ដោយសារគ្រឿងញៀនជាច្រើននាក់ ដែលបច្ចុប្បន្នកំពុងត្រូវការសេវាជួយសង្គ្រោះ ព្យាបាល និងស្តារនីតិសម្បទា ពីស្ថាប័នមានសមត្ថកិច្ច ។

ចំពោះមុខសភាពការណ៍ដ៏គ្រោះថ្នាក់នេះ ដើម្បីរួមចំណែកអនុវត្តកម្មវិធីនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងឈានទៅសំរេចបាននូវផែនការជាតិ ៥ ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រាជរដ្ឋាភិបាល សូមធ្វើការណែនាំដល់គ្រប់ក្រសួង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់ខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានម៉ឺងម៉ាត់នូវវិធានការចាំបាច់មួយចំនួន ដូចខាងក្រោម :

១- អាជ្ញាធរមូលដ្ឋាន ខេត្ត-ក្រុង ជាពិសេសខេត្ត-ក្រុងដែលមានអ្នកញៀនគ្រឿងញៀនច្រើន ត្រូវខិតខំដោះស្រាយរកទីតាំងរៀបចំមជ្ឈមណ្ឌលសំរាប់ទទួលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនអោយបានមួយកន្លែង ដោយសហការជាមួយក្រសួង និងស្ថាប័នជំនាញពាក់ព័ន្ធ ។ ជាមួយនេះត្រូវបំផុសលើកទឹកចិត្តអោយមានការចូលរួមពី សហគមន៍ គ្រួសារ និងអតីតអ្នកញៀនគ្រឿងញៀនសំរាប់ឈានទៅបង្កើតសហគមន៍គ្មានគ្រឿងញៀនមួយជាគំរូ ។

២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរខេត្ត-ក្រុង ដើម្បីគ្រប់គ្រងមជ្ឈមណ្ឌលស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀនដែលបានបង្កើត និងកំពុងដំណើរការនៅទីក្រុងភ្នំពេញ និងនៅតាមខេត្ត-ក្រុង នានា ។

៣- ក្រសួងសុខាភិបាល ត្រូវខិតខំបង្កើតផ្នែកជំនាញព្យាបាលអ្នកញៀនគ្រឿងញៀនថ្នាក់ជាតិ នៅទីក្រុងភ្នំពេញ និងត្រូវរៀបចំអោយមានសេវាពិគ្រោះយោបល់ នៅតាមមន្ទីរពេទ្យបង្អែកខេត្ត-ក្រុង និង ស្រុក សំរាប់ផ្តល់ប្រឹក្សា និងព្យាបាលអ្នកញៀនគ្រឿងញៀន ដែលត្រូវសារអាណាព្យាបាល បានបញ្ជូនទៅកាន់មន្ទីរពេទ្យ ព្រមទាំងបង្កើតបទដ្ឋានបច្ចេកទេសត្រួតពិនិត្យសេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលក្នុងសហគមន៍ និងលុបបំបាត់កន្លែងព្យាបាលជំងឺដែលមិនមានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល ។

៤- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ផ្អែកតាមតម្រូវការថវិកាសំរាប់កសាងមជ្ឈមណ្ឌល និងថវិកាចំណាយចរន្តសំរាប់គាំទ្រសេវាអប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវបញ្ចូលគំរោងថវិកាទាំងនោះ ទៅក្នុងគំរោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ហើយការផ្តល់ថវិកាត្រូវធ្វើឡើងតាមរយៈក្រសួងមហាផ្ទៃដែលជាអាណាប័កដើមខ្សែ ។

៥- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ទទឹមនឹងការពង្រឹងវិធានការទប់ស្កាត់ ការផលិត ការចរាចរហួរចូលគ្រឿងញៀនខុសច្បាប់ និងការប្រើប្រាស់បំពានគ្រឿងញៀន ត្រូវគិតគូររៀបចំទីកន្លែងសមស្របសំរាប់ប្រមូលផ្តុំអ្នកញៀនគ្រឿងញៀន នៅតាមស្នងការដ្ឋាននគរបាល និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត-ក្រុង ដើម្បីព្យាបាល និងអប់រំកែប្រែពួកគេ អោយក្លាយជាពលរដ្ឋល្អរបស់សង្គមជាតិវិញ ។

៦- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការចងក្រងឯកសារមេរៀនអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន ដើម្បីបញ្ជ្រាបបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិទាំងក្នុង និងក្រៅប្រព័ន្ធអប់រំ ចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ហើយត្រូវជំរុញគណៈកម្មការទប់ស្កាត់បាតុភាពអសកម្មក្នុងសាលារៀន និងគ្រឹះស្ថានសិក្សា ដើម្បីទប់ស្កាត់ការជ្រៀតចូលពីសំណាក់ក្រុមជនខិលខូចដែលមកញុះញង់អូសទាញសិស្ស និស្សិត ។

